**AUSTRALIAN EMBASSY**
**PHNOM PENH**

# សេចក្តីប្រកាសពត៌មាន

## <u>អូស្ត្រាលីឧបត្ថម្ភដល់សហគមន៍ដើម្បីលុបបំបាត់អំពើហឹង្សាលើស្ត្រីតាមរយៈ*សំរុះសំរួល*</u>

នាថ្ងៃទី16 ខែមិនា លោកជំទាវឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជា **ម៉ាហ្គារ៉ែត អាដាមសុន** (Margaret Adamson) បានប្រារព្ធពិធីសម្ពោធរបាយការណ៍សិក្សាស្រាវជ្រាវមួយស្តីអំពី ‘ការសំរុះសំរួល និងអំពើហឹង្សាទៅលើស្ត្រី’ ដែលការស្រាវជ្រាវនេះត្រូវបានផ្តល់ថវិការដោយទីភ្នាក់ងារជំនួយអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី AusAID ជាផ្នែកមួយនៃជំនួយរយៈពេលវែងរបស់រដ្ឋាភិបាលអូស្ត្រាលីសំរាប់ប្រព័ន្ធយុត្តិធម៌ឧក្រិដ្ឋកម្មនៅកម្ពុជា។ របាយការណ៍នេះ ត្រូវបានជួលឱ្យរៀបរៀងឡើងដោយ AusAID ដោយសហការជាមួយ និង ទីភ្នាក់ងារអភិវឌ្ឍន៍ដើម្បីស្ត្រីអន្តរជាតិ អង្គការអាដហុក និងអង្គការបន្ទាយស្រី ក្រោមគំរោងចំណាត់ការរបស់សហគមន៍ចំពោះអំពើហឹង្សា។

មានប្រសាសន៍នាពិធីប្រារព្ធបុណ្យទិវាអន្តរជាតិនារី ដែលមានការចូលរួមដោយស្ត្រីជាអ្នកដឹកនាំជាច្រើននោះ លោកជំទាវឯកអគ្គរាជទូត អាដាមសុន បានមានប្រសាសន៍ថា “ការស្រាវជ្រាវក្នុងចំណោមគ្រួសារកម្ពុជាបានបង្ហាញថា មានស្ត្រីដែលរៀបការរួច មួយក្នុងចំណោមប្រាំនាក់ ធ្លាប់បានទទួលអំពើហឹង្សានៅក្នុងគ្រួសារ។ អូស្ត្រាលីកំពុងបំពេញការងារយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នមិនមែនរដ្ឋាភិបាលផ្សេងទៀតដើម្បីកាត់បន្ថយតួរលេខនេះ។ ដោយសារការកាត់បន្ថយអំពើហឹង្សានៅក្នុងគ្រួសារ យើងនឹងធ្វើឱ្យសហគមន៍មានសុវត្ថិភាពជាងមុនសំរាប់មនុស្សគ្រប់គ្នា”។

លោកជំទាវបានមានប្រសាសន៍បន្តថា “អំពើហឹង្សានឹងអាចដោះស្រាយបាន អាស្រ័យដោយការផ្លាស់ប្តូរឥរិយាបថ និងអត្តចរិក ដោយរាប់ទាំងទស្សនៈវាយតំលៃទៅលើឋានៈនាទីរបស់ស្ត្រីនានា។ ការផ្លាស់ប្តូរទាំងនេះត្រូវគិតគូរអំពីការអនុវត្តក្នុងវប្បធម៌របស់កម្ពុជា ដោយរាប់បញ្ចូលទាំងការដែលស្ត្រីជាច្រើនចូលចិត្តទៅរកជំនួយពីអាជ្ញាធរមូលដ្ឋាន មានមេភូមិជាដើម ជាជាងរកដំណោះស្រាយពីថ្នាក់ប៉ូលីស និងតុលាការជាដើម”។

*សំរុះសំរួល* ជាទំរង់លក្ខណៈប្រពៃណីមួយរបស់ជនជាតិកម្ពុជា ក្នុងការដោះស្រាយទំនាស់តាមរយៈការផ្សះផ្សានិងសំរុះសំរួល។ របាយការណ៍នៅក្នុងថ្ងៃនេះ បានរកឃើញថាការអនុវត្តនេះ នៅតែបន្តធ្វើឡើងយ៉ាងទូលំទូលាយនៅក្នុងប្រទេស ដោយសារប្រជាពលរដ្ឋចាត់ទុកថាវាមានភាពងាយស្រួល មានចំណាយទាប និងមានប្រសិទ្ធភាពជាងការដោះស្រាយទំនាស់នៅថ្នាក់លើ។

Villa 11, R.V. Senei Vinnavaut Oum (Former St 254), Chaktaumuk Quarter, Daun Penh District, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

អ្នកស្រាវជ្រាវក៏បានរកឃើញនូវភាពខុសគ្នាយ៉ាងខ្លាំងនូវវិធីសាស្ត្រសំរបសំរួលដែលគេបានប្រើប្រាស់ និងរកឃើញថាអ្នកសំរបសំរួលត្រូវតែមានការយល់ដឹងប្រសើរជាងនេះអំពីសិទ្ធិរបស់ស្ត្រី និងច្បាប់នៅកម្ពុជា ជាពិសេសនៅពេលដោះស្រាយអំពីបញ្ហាហឹង្សានៅក្នុងគ្រួសារ។ របាយការណ៍បានសំណូមពរឱ្យមានការចងក្រងឯកសារណែនាំអំពីការសំរបសំរួលបញ្ហាហឹង្សានៅក្នុងគ្រួសារដោយផ្អែកលើការអនុវត្តដែលជោគជ័យ និងធ្វើការផ្សព្វផ្សាយឱ្យបានពាសពេញផ្ទៃប្រទេស។ របាយការណ៍នេះក៏បានសំណូមពរឱ្យបន្តការចងក្រងទុកឱ្យបានប្រសើរជាងមុន អំពីដំណើការសំរបសំរួល។

រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ស្តីពីហឹង្សានៅក្នុងគ្រួសារនៅឆ្នាំ 2005 ចំណែកផែនការសកម្មភាពជាតិសំរាប់ទប់ស្កាត់អំពើហឹង្សាទៅលើស្ត្រីកំពុងរង់ចាំការអនុម័តពីទីស្តីការគណៈរដ្ឋមន្ត្រី។ ក្រសួងកិច្ចការនារីក៏បានរៀបចំវគ្គបណ្តុះបណ្តាល និងយុទ្ធនាការលើកកំពស់ការយល់ដឹងអំពីវិស័យនេះ សំរាប់មន្ត្រីអនុវត្តច្បាប់ ក្រុមប្រឹក្សាឃុំ និងជាសាធារណៈផងដែរ។ ក៏ប៉ុន្តែ បញ្ហាប្រឈមជាច្រើននៅមាននៅឡើយនៅក្នុងការអនុវត្ត និងការពង្រឹងច្បាប់និងគោលនយោបាយ។

អូស្ត្រាលីកំពុងសហការក្នុងភាពជាដៃគូរដ៏យូរអង្វែងរបស់កម្ពុជា ដើម្បីពង្រឹងការឆ្លើយតបរបស់ប៉ូលីស និងតុលាការ ចំពោះអំពើហឹង្សានៅក្នុងគ្រួសារ និងបង្កើនទំនុកចិត្តរបស់សហគមន៍ទៅលើស្ថាប័នទាំងនេះ។

**ទំនាក់ទំនងការផ្សាយៈ លោកស្រី ហ៊ីយុណា ខស្សូ លេខាទី១**

**ទូរស័ព្ទលេខៈ ០២៣ ២១៣ ៤៧០ ស្ថានទូតអូស្ត្រាលីនៅភ្នំពេញ**

**ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០០៩**